

# ផ្លែដូង និង ដង្វាយមួយភាគក្នុងដប់



ដោយ អាវ៉ាហេ អិម
អាយុ ១១ ឆ្នាំ រស់នៅ
តាហ៊ីទី ប៉ូលីនេស៊ី បារាំង

ជម្រាបសួរ ! ខ្ញុំឈ្មោះ អាវ៉ាហេ ។ ខ្ញុំរស់នៅក្នុងប្រទេសតាហ៊ីទី ! នៅលើកោះរបស់ខ្ញុំ ខ្ញុំចូលចិត្តលេងនៅក្រៅផ្ទះ ។ ខ្ញុំទៅឡើងភ្នំ និងទៅហែលទឹកក្នុងទន្លេ ឬសមុទ្រ ។ ខ្ញុំក៏រីករាយក្នុងការធ្វើអ្វីៗជាមួយក្រុមគ្រួសាររបស់ខ្ញុំផងដែរ ។ ខ្ញុំចូលចិត្តធ្វើម្ហូបអាហារ លេងល្បែងកាត និងឡើងភ្នំ ។ ខ្ញុំចូលចិត្តលេងបាល់ និងឡើងដើមឈើជាមួយបងប្រុស និងបងប្អូនជីដូនមួយរបស់ខ្ញុំ ។

អំឡុងវិស្សមកាលរដូវក្តៅ ខ្ញុំធ្វើការជាមួយបងប្រុសរបស់ខ្ញុំនៅក្នុងចម្ការដូង ។ យើងប្រមូលផ្លែដូង ហើយដាក់ក្នុងគំនរដ៏ធំមួយ ។ យើងក៏ប្រមូលស្លឹកងាប់ៗ ដើម្បីឲ្យចម្ការស្អាតផងដែរ ។

ជីតាទួតរបស់យើងឲ្យប្រាក់មកយើងនៅពេលយើងធ្វើការនៅក្នុងចម្ការ ។ ខ្ញុំតែងតែបង់ដង្វាយមួយភាគក្នុងដប់ជាមួយប្រាក់ដែលខ្ញុំទទួលបានជានិច្ច ។ ខ្ញុំបានរៀនពីគ្រួសាររបស់ខ្ញុំ និងគ្រូថ្នាក់កុមារអំពីរបៀបបង់ដង្វាយមួយភាគក្នុងដប់ ។

ខ្ញុំបង់ដង្វាយមួយភាគក្នុងដប់ពីព្រោះខ្ញុំដឹងថា ក្រុមគ្រួសាររបស់ខ្ញុំ និងខ្ញុំទទួលពរជ័យនៅពេលយើងគោរពតាម ។ ខ្ញុំត្រូវបានប្រទានពរឲ្យមានក្រុមគ្រួសារ ផ្ទះ និងពិភពលោកដ៏ស្រស់ស្អាតនៅជុំវិញខ្ញុំ ។

ខ្ញុំដឹងថា ព្រះមានព្រះជន្មរស់ ហើយថាទ្រង់ស្រឡាញ់ខ្ញុំ ។ ខ្ញុំអរគុណព្រះវរបិតាសួគ៌សម្រាប់ក្រុមគ្រួសារដែលទ្រង់បានប្រទានឲ្យខ្ញុំ ។







### តើដង្វាយមួយភាគក្នុងដប់ជាអ្វី ?

សមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយថ្វាយដង្វាយមួយភាគក្នុងដប់នៃប្រាក់ចំណូលរបស់ពួកគេទៅកាន់សាសនាចក្ររបស់ព្រះ ។ ប្រាក់ដង្វាយរបស់យើងជួយកសាងព្រះវិហារបរិសុទ្ធ និងព្រះវិហារនានា ហើយជួយដល់អ្នកទាំងឡាយណាដែលត្រូវការជំនួយ ។ ដង្វាយមួយភាគក្នុងដប់គឺជារបៀបមួយដែលយើងចែករំលែកពរជ័យរបស់យើងជាមួយមនុស្សដទៃ ។ ព្រះបានប្រទានដល់យើងនូវបទបញ្ញត្តិនេះតាំងពីយូរណាស់មកហើយ នៅក្នុងសម័យកាលព្រះគម្ពីរសញ្ញាចាស់ ( សូមមើល លោកុប្បត្តិ ១៤:១៨–២០ ) ។ ការបង់ដង្វាយមួយភាគក្នុងដប់គឺជារបៀបមួយដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះព្រះវរបិតាសួគ៌ ។



